5297.06
PADD
9/16/99
Cambodian

# Protection & Advocacy, Inc.

**OAKLAND LEGAL OFFICE**
449 15th Street, Suite 401, Oakland, CA 94612-2821
Telephone: (510) 839-0811 Fax: (510) 839-5780
Toll Free/TTY/TDD: (800) 776-5746

Note: When this publication was originally published, we were known as Protection & Advocacy, Inc. (PAI). In October 2008, we changed our name from PAI to Disability Rights California.

## លោកអ្នកអាចទទួលការមើលថែទាំក្មេងពេលថ្ងៃពីមណ្ឌលបំរើតំបន់ !

(You ***Can*** Get Help with Day Care from the Regional Center!)

ក្មេងទាំងឡាយណាដែលឪពុកម្តាយទៅធ្វើការងារ ឬទៅរៀនហ្វឹកហ្វឺននៅសាលារៀន ហើយត្រូវ ការកន្លែងមើលកូនពេលថ្ងៃ។ ការមើលថែទាំក្មេងពិការពេលថ្ងៃ ភាគច្រើន គេយកថ្លៃជាងមើលក្មេង ដែលមិនពិការ ពីព្រោះតែក្មេងខ្លះនោះ ត្រូវការមើលថែទាំពិសេស។ ច្បាប់បានចែងថា មណ្ឌលបំរើ តំបន់ត្រូវតែជួយលោកអ្នកចំពោះតម្លៃយកបន្ថែម នៃការមើលថែទាំក្មេងពេលថ្ងៃ ដែលផ្តល់កិច្ចបំរើ យកថ្លៃសំរាប់មើលក្មេងដែលមិនពិការ (ថ្លៃជួយបង់ – co-pay) ហើយមណ្ឌលបំរើតំបន់ត្រូវតែ បង់ថ្លៃបន្ថែមណាផ្សេងទៀត។ បើសិនជាលោកអ្នកអាចបង្ហាញក្រដាសបញ្ជាក់ពីប្រាក់កាសដែលមានមណ្ឌលបំរើតំបន់ក៏ត្រូវជួយបង់ថ្លៃមួយផ្នែក ឬថ្លៃជួយបង់ទាំងអស់។ ខាងក្រោមគឺជាច្បាប់ទម្លាប់សំខាន់ៗដែលត្រូវធ្វើតាមនៅពេលលោកអ្នកស្នើសុំមណ្ឌលបំរើតំបន់ឲ្យជួយបង់ថ្លៃមើលថែទាំក្មេងពេលថ្ងៃ។

### 1. មណ្ឌលបំរើតំបន់ប្រហែលជាមិនអាចនិយាយថា គេគ្មានបំរើផ្នែកមើលថែទាំក្មេងទេ។

ការមើលថែទាំក្មេងពេលថ្ងៃ គឺជាកិច្ចបំរើមួយដែលច្បាប់បានចែងថា មណ្ឌលបំរើតំបន់ត្រូវតែផ្តល់កិច្ចបំរើនេះ។ ការមើលថែទាំក្មេងពេលថ្ងៃ គឺមិនមានចែងក្នុងច្បាប់, វាជាទូទៅមានន័យថា ការមើលថែទាំក្មេង នៅពេលឪពុកម្តាយក្មេងទៅធ្វើការ ឬទៅរៀនហ្វឹកហ្វឺន។ ក្នុងន័យថា ការមើលថែទាំក្មេងជាបន្ទុករបស់ក្រុមគ្រួសារដែលមានកូននោះ, មណ្ឌលបំរើតំបន់ត្រូវតែជួយក្រុមគ្រួសារដែលត្រូវបង់ថ្លៃ មើលថែទាំក្មេងបន្ថែមពីព្រោះតែកូននោះមានភាពពិការ។

## 2. ចំនួនជំនួយមើលថែទាំក្មេងពេលថ្ងៃ ដែលលោកអ្នកត្រូវបានទទួលនិងបានសម្រេចទៅតាមបុគ្គល ក្នុងក្រុមគ្រួសារលោកអ្នកម្នាក់ៗត្រូវការ។

លោកអ្នកគួរតែស្នើសុំចំនួនម៉ោងលោកអ្នកត្រូវការ ហើយកត់ទុកនូវសេចក្តីត្រូវការនៅក្នុងក្រដាស IPP ឬ IFSP របស់កូនលោកអ្នក។ បើសិនជាមណ្ឌលបំរើតំបន់បដិសេធមិនផ្តល់ឲ្យចំនួនម៉ោងដែលត្រូវការនោះទេ លោកអ្នកអាច ហើយគួរតែឡើងប្តឹងតវ៉ា។ នេះគឺជាសភាពការពិតមួយ បើសិនជាមណ្ឌលបំរើតំបន់ថា គេមានច្បាប់សំរាប់ដាក់តំរិតម៉ោងមើលថែទាំក្មេងតែ 20 ម៉ោងក្នុងមួយអាទិត្យ ឬចំនួនណាមួយផ្សេងទៀត។ យើងជឿថា ការដាក់កំរិតតាមតែអំពើចិត្តលើកិច្ចបំរើ គឺខុសច្បាប់។ នៅពេលលោកអ្នកស្នើសុំកិច្ច បំរើមើលថែទាំក្មេងពេលថ្ងៃ លោកអ្នកគួរតែត្រៀមខ្លួនជាស្រាច់ដើម្បីពិភាក្សារឿងរ៉ាវដូចមានតទៅនេះ :

- **កំណត់ពេល :** លោកអ្នកគួរសរសេរកត់នូវកំណាត់ពេលប្រចាំអាទិត្យនៃការងារ ឬម៉ោងសិក្សានៅ សាលារៀនរបស់លោកអ្នក, រួមទាំងពេលធ្វើដំណើរនៅពេលលោកអ្នកត្រូវការការមើលថែទាំកូន។ នេះកុំបូកបញ្ចូលពេលម៉ោងសំរាក, នៅពេលលោកអ្នកធ្វើកិច្ចក្នុងផ្ទះ, ដើរចរច្រប់, ឬមានពេលឯកខ្លួនចេញពីកូនមួយរយៈ។ ពេលសំរាក គឺអនុញ្ញាតជាកិច្ចបំរើមួយផ្សេងទៀត ដែលលោកអ្នកអាចស្នើសុំបានដូចគ្នាបាន។

- **សេចក្តីត្រូវការពិសេសរបស់កូនលោកអ្នក :** កូនក្មេងដែលគេអាចមើលថែទាំបាននៅក្នុងកម្មវិធីមើលថែទាំក្មេងពេលថ្ងៃ ហើយមានតម្លៃដូចមើលក្មេងអត់ពិការ ដែលមិនទទួលជំនួយពីមណ្ឌលបំរើតំបន់ឲ្យជួយបង់ថ្លៃមើលថែទាំនោះ។ មានការលើកលែងតែមួយគត់ចំពោះរឿងនេះ បើសិនជាក្រុមគ្រួសារលោកអ្នកមិនអាចបង់ថ្លៃមើលថែទាំក្មេងពេលថ្ងៃទេ ហើយនិងពុំមានជំនួយជួយផ្សេងៗទៀតអាចជួយបាន។

  មណ្ឌលបំរើតំបន់មិនអាចប្រាប់លោកអ្នក នៅកន្លែងណាដែលកូនលោកអ្នកគួរទទួលការមើលថែទាំយកថ្លៃខ្ពស់ (ឧទាហរណ៍, មណ្ឌលមិនអាចទទួលយកក្មេងបានច្រើន ពីព្រោះពេលវេលាដែលចំណាយបន្ថែមទៅកូនលោកអ្នក មណ្ឌលត្រូវ

ទិញសម្ភារៈពិសេស ឬប្រដាប់ប្រដារផ្សេង ឬមណ្ឌលត្រូវជួលបុគ្គលិកបន្ថែម), ឬពិភាក្សាពីការមើលថែរក្សាកូនលោកអ្នក, ចិញ្ចឹមបាយទឹក ឬសេចក្តីត្រូវការខាងអាកប្បកិរិយាជាដើម។

- **ការដាក់កូនឲ្យមើលថែរក្សានៅមន្ទីរ :** ច្បាប់បានចែងថា កិច្ចបំរើជួយឧបត្ថម្ភក្រុមគ្រួសារ ដូចជាការមើលថែទាំក្មេងពេលថ្ងៃ គួរតែផ្តល់ឲ្យដល់ក្រុមគ្រួសារ ដើម្បីជួយឧបត្ថម្ភក្នុងការចិញ្ចឹមបីបាច់ក្មេង ដែលពិការនៅនិងផ្ទះរបស់ខ្លួន។ មណ្ឌលបំរើតំបន់ប្រហែលជាសួរ បើសិនជាលោកអ្នកមានបំណងចង់រកវិធីដាក់កូនឲ្យគេមើលថែទាំនៅក្នុងមន្ទីរ បើសិនជាកិច្ចបំរើនោះមិនមានផ្តល់ឲ្យ។ លោកអ្នកគួរតែឆ្លើយប្រាប់គេដោយស្មោះត្រង់ **ប៉ុន្តែកុំមានអារម្មណ៍ថា គេបង្ខំឲ្យគិតពីមធ្យោបាយនេះឲ្យសោះ។**

- **មានការពិបាកចំពោះប្រាក់កាស :** សភាពការពីប្រាក់កាសលោកអ្នក គឺមិនទាក់ទងលុះត្រាតែលោកអ្នកស្នើសុំឲ្យមណ្ឌលបំរើតំបន់ជួយបង់ថ្លៃទាំងអស់ ឬមួយចំណែកនៃថ្លៃជួយបង់លើការ មើលថែទាំក្មេងពេលថ្ងៃ។ បើសិនជាលោកអ្នកមិនផ្តល់ឲ្យនូវឯកសារពីសភាពការនៃប្រាក់កាសលោកអ្នកទេ, លោកអ្នកគួរតែរៀបចំធ្វើក្រដាសរាយថវិកាដែលរួមចូលក្រដាសបញ្ជាក់ពីប្រាក់ ចំណូលក្រោយពីបង់ពន្ធរួច, ប្រាក់ចំណាយទាំងអស់ហើយនិងការចំណាយផ្សេងៗទៀត, ប្រាក់ចំណាយទាំងអស់ដែលទាក់ទងទៅនិងការចំណាយលើការមើលកូនពិការរបស់លោកអ្នក (ថ្លៃពេទ្យ, សម្ភារៈ, ប្រដាប់ប្រដារ, ការធ្វើដំណើរទៅជួបវេជ្ជបណ្ឌិតហើយនិងគ្រូពេទ្យដែលព្យាបាលដោយមិនប្រើថ្នាំ ។ល។), ហើយនិងតម្លៃបង់លើការមើលថែរក្សាកូនពេលថ្ងៃសំរាប់ឲ្យកូនទាំងអស់នៅក្នុងក្រុមគ្រួសារលោកអ្នក។

### 3. សេចក្តីត្រូវការលើការមើលថែរក្សាក្មេងពេលថ្ងៃ ហើយនិងចំនួនកិច្ចបំរើដែលបានផ្តល់អោយ នោះ ត្រូវតែគិតតាមវិធីរបស់ IPP/IFSP ។

នៅពេលលោកអ្នកស្នើសុំការមើលថែទាំក្មេង (ឬកិច្ចបំរើណាផ្សេងៗទៀត), ច្បាប់តម្រូវអោយ ហើយលោកអ្នកត្រូវតែជួយ, ចំពោះអ្នកណាម្នាក់ដែលមានអំណាចផ្តល់ម៉ោងបានស្នើសុំនោះ ត្រូវតែ មកចូលប្រជុំ IPP ឬ IFSP ។ បើសិនជាលោកអ្នកមិនយល់

ស្របនៅពេលប្រជុំទេ ឬអ្នកសម្រេច ភារកិច្ចនៃមណ្ឌលបំរើតំបន់មិនបានមកចូលរួមទេ ក្រុមប្រជុំនេះត្រូវតែដាក់ពេលប្រជុំមួយទៀតនៅក្នុងកំឡុងពេល 15 ថ្ងៃ។ ក្នុងរបៀបនេះ ឪពុកម្តាយរបស់ក្មេងអាចផ្តល់យោបល់របស់ខ្លួនបាន ហេតុអ្វីបានជាគាត់ត្រូវការម៉ោងនោះ ហើយសួរសំណួហើយនិងឆ្លើយតបផ្ទាល់ទៅនិងបុគ្គលដែលជាអ្នកសម្រេចភារៈកិច្ចឲ្យមណ្ឌលបំរើតំបន់តែម្តង។ មណ្ឌលបំរើតំបន់ខ្លះ សាកល្បងធ្វើឲ្យលោកអ្នកធ្វើតាមវិធីលើកលែង ជាទូទៅ គឺការស្នើសុំទៅអ្នកចាងហ្វាងនៃមណ្ឌលបំរើតំបន់ដើម្បីលុបចោលម៉ោងចន្លោះនៃការមើលថែរក្សាក្មេងពេលថ្ងៃដែលមានក្នុងច្បាប់របស់មណ្ឌលបំរើតំបន់។ យើងជឿថា វិធីនេះ គឺជាវិធីបដិសេធឱកាសមិនឲ្យលោកអ្នកនិយាយស្ទីផ្ទាល់ទៅនិងអ្នកសម្រេច ភារៈកិច្ចនោះ ក៏ដូចជាការដាក់កំរិតតាមតែអំពើចិត្ត ទាំងពីរនេះគឺខុសច្បាប់។ បើសិននៅកន្លែងប្រជុំ ក្រុមប្រជុំរកសម្រេចអ្វីមិនកើត, ពួកគេត្រូវតែផ្តល់ព៌តមានឲ្យឪពុកម្តាយក្មេងនូវមូលហេតុអ្វីបានជា មណ្ឌលបំរើតំបន់បដិសេធការស្នើសុំហើយនិងសិទ្ធិឡើងតវ៉ា។ មណ្ឌលបំរើតំបន់បន្ទាប់មកត្រូវតែធ្វើលិខិតស្តីពីការបដិសេធ នោះមកឲ្យឪពុកម្តាយក្មេងក្នុងកំឡុងពេល 5 ថ្ងៃ។